អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២

# សេចក្តីជូនដំណឹង

## សន្និសីទស្តីពីទស្សនវិស័យចម្រុះអំពីកេរដំណែលនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សន្និសីទថ្នាក់ខ្ពស់ស្តីពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងធ្វើឡើងនៅថ្ងៃទី ១៣-១៤ ខែកញ្ញា ឆ្នាំ២០១២ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ក្រោមការរៀបចំរួមគ្នារវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និង គណៈកម្មការប្រព្រឹត្តកម្មនៃអង្គការសមាគម-ការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)។

គោលបំណងនៃសន្និសីទនេះគឺ ដើម្បីលើកកម្ពស់ការពិភាក្សាអំពីកេរដំណែលនៃ អ.វ.ត.ក និងដើម្បីផ្តល់វេទិកាមួយដែលភាគីនីមួយៗនៅក្នុងដំណើរការនេះ ព្រមទាំងសាធារណជនទូទៅ អាចពិចារណាអំពីកេរដំណែលនៃ អ.វ.ត.ក ក្នុងបរិបទជាតិ បរិបទតំបន់ និងបរិបទពិភពលោក។

ក្នុងអំឡុងពេលពីរថ្ងៃនៃសន្និសីទ ចៅក្រមនៃ អ.វ.ត.ក មន្ត្រីរាជរដ្ឋាភិបាល និងអ្នកជំនាញមកពីតុលាការឧក្រិដ្ឋកម្មសង្គ្រាម និងតុលាការយុត្តិធម៌អន្តរជាតិ នឹងពិភាក្សាគ្នាអំពីកេរដំណែលច្បាប់ និងកេរដំណែលសង្គមនៃ អ.វ.ត.ក ផ្តើមចេញពីទស្សនវិស័យចម្រុះ។

ព័ត៌មានលម្អិតអំពីសន្និសីទនិងអំពីវាគ្មិន សូមអាននៅ៖

http://www.eccc.gov.kh/sites/default/files/articles/Legacy%20Conference-brochure-%20KH.pdf

តំណាងសារព័ត៌មានជាតិនិងអន្តរជាតិត្រូវបានអញ្ជើញចូលរួមក្នុងសន្និសីទនេះ។ សូមបង្ហាញប័ណ្ណព័ត៌មាននិងចុះឈ្មោះជាមុននៅមុខច្រកចូលសាលសន្និសីទ ពីម៉ោង ៧:៣០ ដល់ម៉ោង ៨:១៥ ព្រឹកនៃថ្ងៃសន្និសីទ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្រ្តា**
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ: +៨៥៥ (០)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

**លោក សួន ប៊ុនស័ក្ត**
អគ្គលេខាធិការ CHRAC
ទូរស័ព្ទដៃ: +៨៥៥ (០)៩២ ៣៤៤ ៣៥៧
សារអេឡិចត្រូនិក: suonbunsak@yahoo.com

*ឧបត្ថម្ភថវិកាសម្រាប់រៀបចំសន្និសីទនេះដោយ ក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សហព័ន្ធអាល្លឺម៉ង់(BMZ) និង ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក (DANIDA)*